ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១០៤៩ / ... សជ

ថ្ងៃ...ខែ...ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២៥

**សូមគោរពជូន**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** សូមគោរពស្នើសុំគោលការណ៍អនុញ្ញាត ដើម្បីរៀបចំ **«ទិវាជាតិអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី៩ ឆ្នាំ២០២៥»** និងគោរពអញ្ជើញ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត** ជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកម្មវិធីដ៏មានសារសំខាន់នេះ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ក្រោយពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី បានផ្តល់កិត្តិយសអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងកម្មវិធីវេទិកាថ្នាក់ជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២២ លោកបានប្រកាសដាក់បញ្ចូលវេទិកាអន្តរសាសនាថ្នាក់ជាតិ ជា **«ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស»** ដែលនឹងត្រូវប្រារព្ធជារៀងរាល់ឆ្នាំ **នៅថ្ងៃទី២០ ខែសីហា**។ តាំងពីពេលនោះមក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំទិវាជាតិនេះតាមកាលកំណត់។

ទិវាជាតិអន្តរសាសនានេះ គឺជាការពង្រឹងភាពសុខដុមរមនាក្នុងវិស័យសាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ និងសាសនាធំដទៃទៀត ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈសាសនា ដល់សាសនិកទាំងឡាយ ដែលមានជំនឿ និងគោរពសាសនារបស់ខ្លួន។

ឆ្នាំ២០២៥ ជាឆ្នាំទី៩ នៃការប្រារព្ធពិធីនេះ ខ្ញុំបាទសូមគោរពស្នើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី៖**

- រៀបចំ **«ទិវាជាតិអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី៩»** ដ៏មានសារសំខាន់នេះ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ (OCIC)។
- សូមគោរពអញ្ជើញ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត** មេត្តាផ្តល់កិត្តិយសជាអធិបតីដ៏ខ្ពង់ខ្ពស់ ដើម្បីថ្លែងសារដ៏មានសារសំខាន់ និងអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ ជូនមេដឹកនាំសាសនាទាំងអស់ ថ្នាក់ដឹកនាំ គ្រប់ឋានានុក្រម ក្នុងរាជរដ្ឋាភិបាល មន្ត្រីរាជការ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សិស្សនិស្សិត ស្ថានតំណាងបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអង្គការជាតិ-អន្តរជាតិជាដៃគូនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងសាធារណជននៅទូទាំងប្រទេសដែលនឹងអញ្ជើញចូលរួមក្នុងកម្មវិធី ប្រមាណ១៥០០អង្គ/នាក់ បានជ្រាប។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចធិបតីនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**អភិសន្តិបណ្ឌិត ស សុខា**

28.06.25